## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការក្រសួងយុត្តិធម៌**

លេខ ៤០៧ អក.កយ/២០០៥

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>ជម្រាបមក</u>**

## លោក លោកស្រីប្រធានតុលាការខេត្ត ក្រុង
## លោកព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង

**<u>សូមជ្រាប</u>**

**<u>កម្មវត្ថុ:</u>** ស្តីពីការចាត់តាំងឱ្យក្រឡាបញ្ជីចុះទទួលបន្ទុកអនុវត្តសាលក្រម សាលដីកា និងសេចក្តីសម្រេចផ្សេងៗ របស់តុលាការ ។

**<u>យោង:</u>** សេចក្តីបង្គាប់លេខ ១១៧ សរ.វវ ៩៧ ចុះថ្ងៃទី៣១-០១-១៩៩៧ របស់ក្រសួងយុត្តិធម៌ ។

ខ្ញុំសូមជម្រាបអស់លោក លោកស្រីជ្រាបថា យោងតាមសេចក្តីបង្គាប់លេខ១១៧ ដូចមានយោងខាងលើ ក្រសួងយុត្តិធម៌ សម្រេចប្រគល់សមត្ថកិច្ចជូនព្រះរាជអាជ្ញាដឹកនាំអនុវត្តដោយផ្ទាល់ជាបណ្តោះអាសន្ននូវសេចក្តីសម្រេចទាំងអស់ និងដីកាផ្សេងៗទៀត របស់តុលាការគ្រប់ជាន់ថ្នាក់ ក្នុងវង្វង់សមត្ថកិច្ចដែនដីរបស់ខ្លួនទំរាំមានច្បាប់កំណត់អំពីបញ្ហានេះ ប្រសិនបើមានការស្នើសុំត្រឹមត្រូវតាមច្បាប់ពីអ្នកឈ្នះក្តី ឬពីអ្នកទទួលសិទ្ធិពីអ្នកឈ្នះក្តី។ ប៉ុន្តែរយៈពេលកន្លងមកក្រសួងសង្កេតឃើញថា មានអស់លោក លោកស្រី ប្រធានតុលាការ ឬលោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង មួយចំនួនបានសម្រេចចាត់ឱ្យក្រឡាបញ្ជី ទទួលបន្ទុកចុះអនុវត្តនូវសេចក្តីសម្រេចទាំងអស់និងដីកាផ្សេងៗ របស់តុលាការគ្រប់ជាន់ថ្នាក់ ដែលការសម្រេចចាត់តាំងខាងលើនេះ ផ្ទុយនឹងខ្លឹមសារនៃសេចក្តីបង្គាប់លេខ ១១៧ សរ.វវ ៩៧ ចុះថ្ងៃទី៣១-០១-១៩៩៧ របស់ក្រសួងយុត្តិធម៌ ។ ដូច្នេះអំណើះតទៅក្រសួងសុំឲ្យអស់លោក លោកស្រី អនុវត្តឱ្យបានតឹងរឹង និងហ្មត់ចត់តាមខ្លឹមសារនៃសេចក្តីបង្គាប់លេខ១១៧ ដូចមានយោងខាងលើ ។

ក្រសួងយុត្តិធម៌សង្ឃឹមថា អស់លោក លោកស្រី នឹងយកចិត្តទុកដាក់អនុវត្តតាមសេចក្តីណែនាំនេះអោយមានប្រសិទ្ធិភាពខ្ពស់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៥

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍនា**